**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**
**អគ្គនាយកដ្ឋានរដ្ឋបាល**

លេខៈ ០០៤ [illegible]

ថ្ងៃពុធ ៨រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មករា ឆ្នាំ២០២១

# ជម្រាបមក

## ឯកឧត្តម និងលោក លោកស្រីប្រធាននាយកដ្ឋានចំណុះអគ្គនាយកដ្ឋានរដ្ឋបាល

**កម្មវត្ថុ** : ស្តីពីការប្រឡងជ្រើសរើសនិស្សិតអាហារូបករណ៍ ដើម្បីទៅសិក្សានៅប្រទេសហុងគ្រី(HUNGARY) សម្រាប់ឆ្នាំសិក្សា២០២១-២០២២។

**យោង** : លិខិតលេខ ៧១ អយក.សជណ ចុះថ្ងៃសុក្រ ១២កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ក្រសួងអប់រំ យុវជន និងកីឡា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម និងលោក លោកស្រីប្រធាន** ជ្រាបថា សម្រាប់ឆ្នាំសិក្សា២០២១-២០២២នេះ រដ្ឋាភិបាលនៃសាធារណរដ្ឋហុងគ្រីនឹងផ្តល់អាហារូបករណ៍ចំនួន១៥កន្លែង ដល់និស្សិតកម្ពុជាដើម្បីទៅបន្តការសិក្សានៅតាមសាកលវិទ្យាល័យនានាក្នុងប្រទេសហុងគ្រី ក្រោមកម្មវិធីអាហារូបករណ៍ Stipendium Hungaricum Programme ចាប់ពីឆ្នាំ២០២១តទៅ។ ចំពោះប្រភេទអាហារូបករណ៍ដែលផ្តល់ឱ្យរួមមានៈ

១. ថ្នាក់បណ្ឌិត ចំនួន០២កន្លែង : លើគ្រប់មុខជំនាញ (សិក្សាជាភាសាហុងគ្រីឬអង់គ្លេស)
២. ថ្នាក់អនុបណ្ឌិត ចំនួន០៥កន្លែង : លើមុខជំនាញកសិកម្ម វិស្វកម្ម សេដ្ឋកិច្ច សិល្បៈ និងវិទ្យាសាស្រ្តធម្មជាតិ
៣. ថ្នាក់បរិញ្ញាបត្រ ចំនួន០៥កន្លែង : លើមុខជំនាញកសិកម្ម មនុស្សសាស្រ្ត វិស្វកម្ម សេដ្ឋកិច្ច និងវិទ្យាសាស្រ្តធម្មជាតិ
៤. អាហារូបករណ៍ ចំនួន០១កន្លែង : សិក្សាពេញមួយចប់ក្នុងមុខជំនាញណាមួយ
៥. អាហារូបករណ៍រយៈពេល២០ខែ : សម្រាប់បណ្តុះបណ្តាលជំនាញដែលបង្រៀនជាភាសាអង់គ្លេសដល់និស្សិតដែលមានសញ្ញាបត្រឯកទេស។

ចំពោះថ្លៃសិក្សា ប្រាក់អាហារូបករណ៍ប្រចាំខែសម្រាប់ផ្គត់ផ្គង់ការរស់នៅ កន្លែងស្នាក់នៅ រ៉ាប់រងសេវាសុខភាព និងអត្ថប្រយោជន៍ផ្សេងៗទៀតជាបន្ទុករបស់រដ្ឋាភិបាលនៃសាធារណរដ្ឋហុងគ្រី។

បេក្ខជនដែលមានបំណងចូលរួមប្រឡងក្នុងកម្មវិធីអាហារូបករណ៍ខាងលើ ត្រូវដាក់ពាក្យតាម Online តាមរយៈគេហទំព័រ apply.stipendiumhungaricum.hu ឬ www.stipendiumhungaricum.hu ឱ្យបានមុនថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១។ ទន្ទឹមនេះបេក្ខជនក៏តម្រូវឱ្យមកចុះឈ្មោះនៅការិយាល័យអាហារូបករណ៍ និងកម្មវិធីសិក្សា នៃនាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ ដែលមានអាសយដ្ឋានអគារលេខ៨០ មហាវិថីព្រះនរោត្តម (ស្ថិតក្នុងទីស្តីការក្រសួងអប់រំ យុវជន និងកីឡា) ចាប់ពីថ្ងៃផ្សាយដំណឹងនេះតទៅ រហូតដល់ថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ វេលាម៉ោង១៦:០០នាទី និងព័ត៌មានទាក់ទងនឹងលក្ខខណ្ឌ

នៃការចូលរួមជាបេក្ខភាព និងការបំពេញឯកសារផ្សេងៗសូមមើលនៅក្នុងគេហទំព័រខាងលើ ឬទំនាក់ទំនងតាមរយៈទូរស័ព្ទលេខៈ ០២៣ ២១០ ៥៥៤។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម** និង**លោក លោកស្រីប្រធាន** ជ្រាប និងចាត់ចែងផ្សព្វផ្សាយដល់មន្ត្រីរាជការ ក្រោមឱវាទ ឱ្យបានទូលំទូលាយតាមការគួរ។

សូម **ឯកឧត្តម** និង**លោក លោកស្រីប្រធាន** ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**អគ្គនាយក**

ប្រាក់ សំអឿន

<u>សូមទំនាក់ទំនងៈ</u>

- លោក ហេង ច័ន្ទសុភារិទ្ធ
- ទូរស័ព្ទលេខៈ ០១២ ៨៣៣ ៨៧៤